# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាឱកាសតែងតាំងមុខងារបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពតាខ្មៅ
# ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨

*ព្រះយេស៊ូគង់នៅជាមួយយើង*

| |
|---|
| អត្ថបទទី១៖ ទក ៤,៣២-៣៤.៣៩-៤០<br>អត្ថបទទី២៖ រម ៨,១៤-១៧<br>ដំណឹងល្អ៖ មថ ២៨,១៦-២០ |

បងប្អូនជាទីស្រឡាញ់!

នៅពេលយើងចាប់ផ្តើមអធិដ្ឋាន នៅពេលយើងចាប់ផ្តើមចូលអភិបូជា នៅពេលយើងចាប់ផ្តើមជួបជុំគ្នាជាគ្រីស្តបរិស័ទ យើងជម្រាបសួរព្រះយេស៊ូ គឺដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងគូសសញ្ញាឈើឆ្កាង ដោយនឹកឃើញដល់ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ នេះជារបៀបដែលយើងជម្រាបសួរព្រះជាម្ចាស់។ នេះជារបៀបដែលយើងចាប់ផ្តើមបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់របស់យើង។

នៅថ្ងៃដែលយើងទទួលពិធីជ្រមុជទឹក យើងចាក់ទឹកលើក្បាល ហើយនៅពេលនោះលោកឪពុកនិយាយថា "**ខ្ញុំជ្រមុជកូនដោយនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ**"។ ដើម្បីអនុវត្តព្រះបន្ទូលដែលព្រះយេស៊ូមានថ្ងៃនេះ មុនព្រះយេស៊ូចេញពីពិភពលោកនេះ ព្រះយេស៊ូបាននិយាយទៅកាន់ក្រុមគ្រីស្តទូត "**សូមទៅពីកន្លែងមួយទៅកន្លែងមួយ ពីភូមិមួយទៅភូមិមួយ ដើម្បីឲ្យមនុស្សមួយចំនួនស្គាល់ខ្ញុំ និងធ្វើពិធីជ្រមុជទឹកឲ្យគេ ដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ**"។ ជាអ្វីដែលបានកើតឡើងនៅមណ្ឌលតាខ្មៅរបស់យើង មណ្ឌលនេះដែលខ្ញុំបង្កើតថ្មីកាលពីបីឆ្នាំមុន។ ចាប់ផ្តើមមុនគេបង្អស់នៅគងនយ ប្រហែលជិត២០ឆ្នាំហើយ និងថ្ងៃនេះយើងមានមីងតុល ជាមួយសុខជា និងបងប្អូនមួយចំនួនដែលសព្វថ្ងៃជាគ្រីស្តបរិស័ទ បានណែនាំឲ្យបងប្អូនស្គាល់ព្រះយេស៊ូតទៅទៀត។ យើងមានវិហារនៅគងនយ ជាសញ្ញាសម្គាល់យើងជាគ្រីស្តបរិស័ទ យើងបានប្រកាសដំណឹងល្អ យើងបានប្រមូលមនុស្សមួយចំនួន ដើម្បីឲ្យគេស្គាល់ព្រះយេស៊ូ និងឲ្យគេមានអំណរសប្បាយជាមួយព្រះអង្គ។ យើងអនុវត្តន៍នូវអ្វីដែលព្រះយេស៊ូបាននិយាយ និងរាល់ពីរឬបីឆ្នាំម្តង យើងមានពិធីជ្រមុជទឹក ដោយសារមានពូមីង និងយុវជនយុវនារីមួយចំនួននៅគងនយ ដើរតាមព្រះយេស៊ូ និងទទួលជីវិតតាមរយៈលោកឪពុក។

ព្រះសហគមន៍បន្តនៅអំពៅព្រៃ បានចាប់ផ្តើមនៅឆ្នាំ២០១០ ដែលចាប់ផ្តើមប្រកាសដំណឹងល្អដូចគ្នា ដើម្បីឲ្យមានយុវជនមួយចំនួន។ ព្រះសហគមន៍នេះ មានឈ្មោះពីរោះណាស់ "**ព្រះយេស៊ូសង្គ្រោះមនុស្សលោក**" នេះជាព្រះសហគមន៍អំពៅព្រៃ ដែលបានចាប់ផ្តើមជាមួយអ្នកគ្រូថារី ជាមួយលោកឪពុកដើម្បីឲ្យមីងពូមួយចំនួន ស្គាល់ព្រះយេស៊ូ មានជីវិត ដោយនៅកន្លែង

នោះអត់ទាន់មានវិហារទេ ប៉ុន្តែយើងមានបន្ទប់ប្រជុំ ដែលរាល់អាទិត្យយើងអធិដ្ឋាន អភិបូជា ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងដើម្បីបម្រើអ្នកក្រីក្រ បម្រើកូនក្មេង និងយុវជនតទៅទៀត។

ឥលូវយើងមកដល់តាខ្មៅនេះ កន្លែងនេះពិសេសវិហារក៏មិនទាន់មាន មានតែបន្ទប់អធិដ្ឋានមួយ។ ភូមិភាគភ្នំពេញនៅសម័យនោះ មានមណ្ឌលសកម្មភាព៧ និងឆ្នាំ២០១៤ ថ្ងៃទី០១ ខែមករា យើងបង្កើតមណ្ឌលថ្មី២គឺ ទី១ភ្នំពេញថ្មី ដែលមានកំពង់ស្ពឺ និងពោធិ៍ចិនតុង។ ទី២ មណ្ឌលសកម្មភាពតាខ្មៅ មានគងនយ និងអំពៅព្រៃ។ លោកឪពុកចាប់ផ្ដើមមានសកម្មភាពខ្លះៗ នៅតាខ្មៅនេះ ដោយចាប់ផ្ដើមទៅសួរសុខទុក្ខតាមភូមិ មានពូៗមីងៗ កូនមត្តេយ្យ ឡាវ៉ាឡា។ ចាប់ផ្ដើមដោយមានកូនក្មេង និងក្រោយមកមានកម្មវិធីសាលាមត្តេយ្យ ទៅសួរសុខទុក្ខអ្នកជំងឺ អ្នកក្រីក្រ បងប្អូនដែលអត់មានសមត្ថភាពដូចគេ។ យើងបានចាប់ផ្ដើមភ្ជាប់គ្នារហូតបន្តិចម្ដងៗ យើងអាចនិយាយថា ព្រះសហគមន៍តាខ្មៅបានកើតឡើងដោយមានពិធីជ្រមុជទឹកខ្លះៗ ជាពិសេសនៅខាងឡាវ៉ាឡា បានទទួលជីវិតពីព្រះយេស៊ូ។ ដូច្នេះយើងបានបង្កើតគ្រួសារមួយរួមជាមួយបងប្អូនដើម្បី ណែនាំមនុស្សទាំងអស់ អាចរកឃើញសេចក្ដីសុខសាន្តនៅក្នុងជីវិត ដូចពេលយើងជួបជុំគ្នានៅថ្ងៃនេះ នៅពេលយើងមានកម្មវិធីសម្រាប់កូនក្មេង នៅពេលយើងទៅសួរសុខទុក្ខអ្នកជំងឺ នៅពេលយើងជួបជុំគ្នាដើម្បីចែករំលែកអំពីជីវិតរបស់យើង នោះយើងរកឃើញសេចក្ដីសុខ។ សេចក្ដីសុខនេះពិសេស ដោយសារមកពីព្រះជាម្ចាស់ផ្ទាល់ និងព្រះជាម្ចាស់របស់យើង ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

ដូច្នេះ ថ្ងៃនេះដើម្បីតែងតាំងលោកឪពុកដើម្បីសម្រុះសម្រួលមណ្ឌលនេះ លោកឪពុកត្រូវតែនឹកឃើញដល់ព្រះជាម្ចាស់ ដោយសារលោកឪពុកជាតំណាងរបស់ព្រះជាម្ចាស់នៅទីនេះតែម្ដង។ ហេតុនេះហើយ សូមឲ្យមានទឹកចិត្តដូចព្រះជាម្ចាស់ ជាទឹកចិត្តឪពុក។ ព្រះជាម្ចាស់ស្រឡាញ់យើង ថែរក្សាយើង អប់រំយើង ការពារយើង ណែនាំឲ្យយើងដើរតាមផ្លូវជីវិតដូចឪពុកបង្កើត។ ឥលូវនេះយើងមានឪពុកពីរនាក់ ដែលអាចណែនាំឲ្យយើងទទួលសេចក្ដីសុខ ឲ្យយើងទទួលការអប់រំ ឲ្យយើងមើលឃើញអនាគតថាត្រូវធ្វើអ្វីខ្លះ? ឲ្យឪពុកចាប់ដៃដើម្បីណែនាំក្នុងការធ្វើដំណើរ ដូចព្រះបិតាចាប់ដៃរបស់យើង លើកលែងទោសឲ្យយើង និងណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតដ៏ពេញលក្ខណៈ។ ថ្ងៃនេះយើងគោរពព្រះយេស៊ូ ដែលជាព្រះបុត្រា ហេតុនេះហើយលោកឪពុកគឺដូចព្រះយេស៊ូ ទៅជាមិត្តសម្លាញ់ ជាបងប្អូនរបស់បងប្អូនទាំងអស់នៅទីនេះ។ យើងជាបងនៅក្នុងជំនឿ ដើម្បីណែនាំឲ្យក្រុមគ្រួសារដ៏ធំនេះរកឃើញសេចក្ដីសុខទាំងមិត្តភាព និងទាំងជីវិតជាបងប្អូន។ មិត្តភាពដោយសារព្រះយេស៊ូមានព្រះបន្ទូលថា "**ឥលូវនេះខ្ញុំជ្រើសរើសបងប្អូនទាំងអស់ទៅជាមិត្តសម្លាញ់របស់ខ្ញុំ**"។ ព្រះយេស៊ូមិនឆ្ងាយពីយើងទេ គឺជាមិត្តសម្លាញ់របស់

យើង។ ជាមួយមិត្តសម្លាញ់យើងមានភាពកក់ក្ដៅ ដោយអាចចែករំលែកអ្វីៗទាំងអស់ដែលយើងមាននៅក្នុងចិត្ត ទុក្ខលំបាក អំណរសប្បាយ សេចក្ដីសង្ឃឹម ការឈឺចាប់ និងអ្វីៗទាំងអស់។ យើងអាចចែករំលែកសេចក្ដីសុខយើង ទុក្ខលំបាកយើង សំណួរយើង ដើម្បីទទួលបានភាពកក់ក្ដៅដូចបងបង្កើត។ ជាបងបង្កើតទៅជាមិត្តសម្លាញ់មួយយ៉ាងពិសេសដែលមានចិត្តស្មោះ ដែលស្រឡាញ់យើង នាំឲ្យយើងមានជីវិត និងសេចក្ដីសង្ឃឹមជានិច្ច។ ហើយនេះអាចធ្វើបាន ប្រសិនបើយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ជាដង្ហើមរបស់ព្រះជាម្ចាស់ ជាវិញ្ញាណរបស់ព្រះជាម្ចាស់ដើម្បីណែនាំឲ្យយើងមានគំនិតថ្មីៗ ដើម្បីឲ្យព្រះសហគមន៍របស់យើង។

លោកឪពុកដើរតាមផ្ទះនីមួយៗទៅសួរសុខទុក្ខ មានព្រះវិញ្ញាណដ៏វិសុទ្ធជំរុញឲ្យដើរតាមភូមិ ដោយមិនមែនជាប់តែជាមួយវិហារ ជាប់ជាមួយកន្លែងដែលយើងជួបជុំគ្នា ឲ្យគ្រីស្តបរិស័ទមកដល់យើង។ តែយើងទៅដល់គ្រីស្តបរិស័ទ និងបងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទដែរ។ យើងទៅដល់កន្លែងនីមួយៗដើម្បីទៅសួរសុខទុក្ខ ដើម្បីបង្កើតទំនាក់ទំនង ដោយដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធជាសេចក្ដីស្រឡាញ់ ជំរុញយើងឲ្យយើងបំពេញដោយបេសកកម្មដែលព្រះយេស៊ូឲ្យយើងទទួល។ យើងមានចិត្តដូចប៉ា ដូចបង និងក្រោយមកព្រះវិញ្ញាណដ៏វិសុទ្ធទៅជាកម្លាំងមួយ ពោរពេញដោយសេចក្ដីស្រឡាញ់សម្រាប់បងប្អូនទាំងអស់ ដើម្បីឲ្យបងប្អូនទាំងអស់រស់នៅក្នុងសេចក្ដីសុខ។ នៅក្នុងព្រះសហគមន៍ដែលមានលោកអភិបាល មិនអាចដឹកនាំកន្លែងនីមួយៗផ្ទាល់។ ដូច្នេះខ្ញុំប្រគល់តួនាទីខ្ញុំគឺះ **អប់រំ** ណែនាំគ្រីស្តបរិស័ទឲ្យទៅជាគ្រីស្តបរិស័ទដ៏វិសុទ្ធ។ **គ្រប់គ្រង** គ្រប់គ្រងកន្លែង គ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងមនុស្ស។

**អប់រំឲ្យមនុស្សស្គាល់ព្រះជាម្ចាស់** បន្ទាប់មក**ណែនាំឲ្យបងប្អូនទៅជាមនុស្សដ៏វិសុទ្ធតាមរយៈអគ្គសញ្ញានីមួយៗ** និង**គ្រប់គ្រង**។ ព្រះសហគមន៍ គឺមានបងប្អូនទាំងអស់ សូមជួយធ្វើជាគ្រីស្តទូតពិតៗ ដើម្បីឲ្យតាខ្មៅបានទទួលជីវិតធ្វើតាមព្រះយេស៊ូ។ សហការយ៉ាងជិតស្និទ្ធជាមួយបងប្អូនទាំងអស់ ដើម្បីឲ្យនៅក្នុងព្រះសហគមន៍ ជាមួយបងប្អូនទាំងអស់ ដើម្បីឲ្យយើងទាំងអស់យល់ថាព្រះសហគមន៍ជាគ្រួសាររបស់យើង ជាផ្ទះរបស់យើង ហើយយើងជាម្ចាស់ផ្ទះរួមជាមួយគ្នា។ ជាម្ចាស់ផ្ទះ ដែលណែនាំឲ្យយើងទទួលបងប្អូនដោយកក់ក្ដៅ យ៉ាងរាក់ទាក់គ្រប់ពេលវេលាដោយធ្វើឲ្យកន្លែងរបស់យើងអត់បិទទ្វារ អត់បិទរបងដើម្បីឲ្យបងប្អូនចេញចូលនៅក្នុងសេចក្ដីសុខ ជាគ្រួសារមួយដែលចេះស្វាគមន៍ ដែលចេះស្រឡាញ់ ដែលចេះអាណិតមេត្តា និងដែលចេះលើកលែងទោសជានិច្ច។

ថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ ដោយសារយើងកក់ក្ដៅណាស់ យើងសប្បាយចិត្តណាស់។ នៅពេលយើងគូសសញ្ញាឈើឆ្កាង ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ កុំភ្លេចថាយើងភ្ជាប់ជាមួយព្រះយេស៊ូ យើងចូលទៅក្នុងផ្ទះរបស់យើង ដែលជាគ្រួសាររបស់យើង ដែលណែនាំឲ្យយើងកក់ក្ដៅ ដោយសារយើងមានប៉ា ដោយសារយើងមានបងដោយសារយើងមានព្រះវិញ្ញាណដ៏វិសុទ្ធដែលជាសេចក្ដីស្រឡាញ់ ដោយសារយើងមានគ្រួសារមួយដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីបង្កើតជីវិតរបស់ព្រះជាម្ចាស់។ ណែនាំឲ្យព្រះសហគមន៍របស់យើងនៅតាខ្មៅនេះ រីកចម្រើននៅក្នុងសេចក្ដីសុខ អនុវត្តន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ "សូមទៅប្រកាសដំណឹងល្អ ព្យាបាលអ្នកជំងឺ និងណែនាំឲ្យមនុស្សដែលអស់សង្ឃឹមមានសេចក្ដីសង្ឃឹម ធ្វើពិធីជ្រមុជទឹកឲ្យគេទៅ ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ដោយដឹងថាព្រះយេស៊ូគង់នៅជាមួយយើងជានិច្ច។ អាម៉ែន៕